# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥

## ជប៉ុនផ្តល់ ២៤០,៦៤៤ ដុល្លារអាមេរិក សម្រាប់គម្រោងពង្រឹងសមត្ថភាពកំណត់រោគវិនិច្ឆ័យជម្ងឺរបេង នៅស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង កម្ពុជាដំណាក់កាលទី២



ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាសរុបចំនួន ២៤០,៦៤៤ ដុល្លាអាមេរិក ដល់សមាគមកំចាត់រោគរបេងជប៉ុន (JATA)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក កូបាយ៉ាស៊ី ស៊ីហ្គិអូ អនុប្រធានការិយាល័យJATAនៅកម្ពុជា នៅស្ថានទូតជប៉ុន ដើម្បីអនុវត្ត "គម្រោងពង្រឹងសមត្ថភាពកំណត់រោគវិនិច្ឆ័យជម្ងឺរបេង ក្នុងស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង កម្ពុជាដំណាក់កាលទី២"។



ក្នុងដំណាក់កាលទី១ JATA បានដំឡើងបរិក្ខារវេជ្ជសាស្ត្រ សម្រាប់រោគវិនិច្ឆ័យនៃជម្ងឺរបេង និងបានអនុវត្តកម្មវិធីបណ្តុះបណ្តាលដល់ក្រុមនៃផ្នែកគ្រប់គ្រងជម្ងឺរបេង បុគ្គលិក និង អ្នកស្ម័គ្រចិត្តរបស់មណ្ឌលសុខភាពនានា និងមន្ទីរពេទ្យបង្អែកពារាំង។ ក្នុងដំណាក់កាលទី២នេះ ដោយផ្អែកលើសកម្មភាពនៃដំណាក់កាលទី១ JATA មានគម្រោងក្នុងការផ្តល់កម្មវិធីបណ្តុះបណ្តាលជាបន្តទៅទៀតដល់បុគ្គលដែលពាក់ព័ន្ធ។ បន្ថែមលើនេះ JATA ក៏នឹងផ្តល់កម្មវិធីបណ្តុះបណ្តាលផ្នែកបច្ចេកទេសដល់គ្រូពេទ្យវេជ្ជសាស្ត្រ និងគ្រូពេទ្យផ្នែកវិទ្យុសកម្មផងដែរ។ ជាមួយនឹងគម្រោងនេះ ការកំណត់រោគវិនិច្ឆ័យ និងប្រព័ន្ធព្យាបាលវេជ្ជសាស្ត្រ នឹងត្រូវបានពង្រឹង ហើយអត្រានៃការឆ្លងមេរោគរបេងក្នុងតំបន់គោលដៅទាំងនោះ នឹងត្រូវបានកាត់បន្ថយ។



កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តារនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង២២.៥លានដុល្លាអាមេរិក ដល់គម្រោងចំនួន៨៣គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី៥តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៤ របស់ជប៉ុន(មេសា២០១៤ ដល់ មិនា២០១៥)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល:* eco.jpn@pp.mofa.go.jp
*គេហទំព័រ:* http://www.kh.emb-japan.go.jp